**សុន្ទរកថា**
**របស់ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងនៃក្រសួងបរិស្ថាន**
**ក្នុងកិច្ចប្រជុំក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ**
សណ្ឋាគារកាំបូឌីយ៉ាណា ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤

- **សូមស្វាគមន៍ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ជាក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ**

ជាបឋមជួសមុខឱ្យឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថានដែលជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម លោកជំទាវ លោកលោកស្រីទាំងអស់ដែលជាសមាជិកសមាជិកានៃក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុអន្តរក្រសួងដែលបានអញ្ជើញមកចូលរួមនៅក្នុង "**កិច្ចប្រជុំក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ**" ដ៏មានសារៈសំខាន់នាព្រឹកនេះ។

ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ជ្រាបថា កាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅវិមានសន្តិភាព ក្នុងឱកាសនៃពិធីបើកវេទិកាជាតិលើកទី៣ស្តីពីការប្រែប្រួលអាកាសធាតុ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា** បានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ**ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣។ ផែនការយុទ្ធសាស្ត្រជាតិដែលមានរយៈពេល១០ឆ្នាំ**នេះគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយ និងជាត្រីវិស័យមួយ សម្រាប់ឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា ឱ្យបានត្រឹមត្រូវទៅតាមអាទិភាពជាតិ។ ឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រជាតិនេះក្រសួងចំនួន១០បានរៀបចំនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួល និងផែនការសកម្មភាពតាមវិស័យនានានៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ហើយមិនតែប៉ុណ្ណោះ ផែនការទាំងនោះត្រូវបានបញ្ជ្រាបចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(២០១៤-២០១៨)ដែលរាជរដ្ឋាភិបាលកម្ពុជាទើបនឹងដាក់ចេញឱ្យអនុវត្តជាផ្លូវការកាលពីពេលកន្លងទៅថ្មីៗនេះ សំដៅរួមចំណែកឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ បើទោះបីជាមានការប្រែប្រួលអាកាសធាតុក៏ដោយ។ ផែនការសកម្មភាពទាំងអស់នោះ ត្រូវបានស្វាគមន៍ និងមានការគាំទ្រពីដៃគូអភិវឌ្ឍន៍មួយចំនួន ទាំងនេះគឺជាឱកាសមួយសម្រាប់ទាក់ទាញបាននូវធនធានពីដៃគូអភិវឌ្ឍនានា សម្រាប់អនុវត្តការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ តាមក្រសួង/ស្ថាប័នជំនាញរបស់ឯកឧត្តម លោក លោកស្រី។

**ឯកឧត្តមអស់លោកលោកស្រីជាទីមេត្រី**!

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាជំហានទី១ត្រូវបានបញ្ចប់ទៅដោយជោគជ័យគួរឱ្យកត់សំគាល់ដែលរួមមានទាំង ការរៀបចំផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ផែនការ (.ក.អ.ប.យ.ផ) សកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ វេទិកាគ្រប់គ្រងចំណេះដឹង និងគម្រោងសាកល្បងបន្សាំនឹងការប្រែប្រួលអាកាសធាតុចំនួន២០ដែលបានជួយដល់សហគមន៍មូលដ្ឋានក្នុងការកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងមានការកោតសសើរពីសំណាក់ដៃគូរអភិវឌ្ឍន៍នានា និងបានចងក្រងនូវមេរៀនជាបទពិសោធន៍ជាច្រើនសម្រាប់អនុវត្តបន្តទៀត។

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាជំហានទី២បានចាប់ផ្ដើមអនុវត្តចាប់ពីខែកក្កដា ឆ្នាំ២០១៤រហូតដល់ខែមិថុនាឆ្នាំ២០១៩ ដែលមានទឹកប្រាប់ប្រមាណ១២,៤លានដុល្លាអាមេរិកដោយផ្ដោតលើលទ្ធផលចំនួន៣ធំ១)ក្របខណ្ឌអភិបាលកិច្ច និងគណនេយ្យភាពច្បាស់លាស់សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោម ជាតិ។ ២)ហិរញ្ញវត្ថុពីប្រភពក្នុងប្រទេស និងពីក្រៅប្រទេស ដែលមានប្រសិទ្ធិភាពដល់ការគាំទ្រការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ និងបញ្ជ្រាបញ្ញកាបូនតិច។៣) ពង្រឹងសមត្ថភាពមនុស្ស និងបច្ចេកទេស សម្រាប់គាំទ្រដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ នៅក្នុងនោះដែរ គម្រោងនឹងមានការគាំទ្រដល់ក្រសួងស្ថាប័ន ដែលបានរៀបចំនូវផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យមួយចំនួនដោតក្នុងការអនុវត្តនូវផែនការសកម្មភាពទាំងនោះ និងផ្តល់ថវិកាមួយចំនួនទៀតសម្រាប់ការអនុវត្តគម្រោងសិក្សាស្រាវជ្រាវ របស់គ្រឹះស្ថានសិក្សា វិទ្យាស្ថានសិក្សាស្រាវជ្រាវ អង្គការសង្គមស៊ីវិល។

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា កិច្ចប្រជុំនាថ្ងៃនេះនឹងជួយផ្តល់លក្ខណៈវិនិច្ឆ័យសម្រាប់ចាត់អទិភាពនូវវិស័យមួយចំនួនសម្រាប់ទទួលនូវកញ្ចប់ថវិកាអនុវត្តគម្រោងពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី២សម្រាប់ជួយជាធាតុចូល និងជួយដល់លេខាធិការដ្ឋានមូលនិធិសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។ ខ្ញុំសូមសំណូមពរឱ្យក្រុមការងារមេត្តាពិនិត្យ ពិភាក្សាគ្នាឱ្យបានផុសផុល ដើម្បីឱ្យការផ្តល់កញ្ចប់ថវិការបស់យើងបានឆ្លើយតបទៅនឹងតម្រូវការពិតប្រាដករបស់ប្រទេសកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលអញ្ជើញមកចូលរួមក្នុងប្រជុំនេះ។ សូមអរគុណដល់មន្ត្រីនាយកដ្ឋានប្រែប្រួលអាកាសធាតុ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដែលបានខិតខំរៀបចំ និងគាំទ្រផ្នែកហិរញ្ញវត្ថុដល់កិច្ចប្រជុំនេះ ឱ្យចេញជារូបរាងឡើង។ ខ្ញុំសូមជូនពរឲ្យកិច្ចប្រជុំនេះ ឱ្យទទួលបានជោគជ័យ និងសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ទទួលបាននូវជោគជ័យគ្រប់ភារៈកិច្ច។

**សូមអរគុណ**